ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

លេខ: ០៣៥ សក.សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មការចំពោះកិច្ចដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការងារត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់

## រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០០៩ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងមុខតំណែងឥស្សរជនជារដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការនៃក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០៤៤ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងមុខតំណែងរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៩៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការផ្ទេរ និងតែងតាំងមុខតំណែងរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីផ្លូវថ្នល់
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ២២០ អនក្រ.បក ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដំឡើងនាយកដ្ឋានសំណង់ប្រព័ន្ធចម្រោះទឹកកខ្វក់ទៅជាអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១ ស្តីពីការប្រែក្លាយ និងដំឡើងវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេសសាធារណការ និងដឹកជញ្ជូនទៅជាវិទ្យាស្ថានតេជោសែនសាធារណការ និងដឹកជញ្ជូនរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការដំឡើងនាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈទៅជាអគ្គនាយកដ្ឋានបច្ចេកវិទ្យា និងទំនាក់ទំនងសាធារណៈ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤១ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា១៥ នៃអនុក្រឹត្យលេខ ១៤១ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- បានឃើញប្រកាសលេខ ២៧៤ ប្រក.សក ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងគណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- បានឃើញប្រកាសលេខ ០៥០ ប្រក.សក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០ ស្តីពីការតែងតាំងសមាសភាពមន្ត្រីលេខាធិការដ្ឋានរបស់គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- បានឃើញសេចក្តីសម្រេចលេខ ៨២ សសរ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីការចាត់តាំងរដ្ឋលេខាធិការប្រចាំការនៃក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញសេចក្តីសម្រេចលេខ ០២៣ សសរ.សក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ ស្តីពីរបៀបរបបការងារ និងការបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញសេចក្តីសម្រេចលេខ ០២៥ សក.សសរ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការបែងចែកភារកិច្ចបន្ថែមជូនថ្នាក់ដឹកនាំក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញសេចក្តីសម្រេចលេខ ០៣៥ សក.សសរ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការបែងចែកភារកិច្ចបន្ថែមជូនថ្នាក់ដឹកនាំក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការចំពោះកិច្ចដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការងារត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ដែលហៅកាត់ថា "គណៈកម្មការចំពោះកិច្ច" រួមមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ប៉េង ពោធិ៍នា** | រដ្ឋមន្ត្រី | ប្រធាន |
| ២. លោកជំទាវ **ភុយ សុជានី** | រដ្ឋលេខាធិការប្រចាំការ | អនុប្រធាន |
| ៣. ឯកឧត្តម **លឹម ស៊ីដេនីន** | រដ្ឋលេខាធិការ | សមាជិក |
| ៤. ឯកឧត្តម **ផែន សុវិជ្ជាសោ** | រដ្ឋលេខាធិការ | សមាជិក |
| ៥. ឯកឧត្តម **ប៉ាល់ ចន្ទតារា** | រដ្ឋលេខាធិការ | សមាជិក |
| ៦. ឯកឧត្តម **សេខ ឈួន** | រដ្ឋលេខាធិការ | សមាជិក |

តេឡេក្រាម ឯកសាររដ្ឋបាលសាធារណៈ - https://t.me/oa_channel

| | | |
|---|---|---|
| ៧. ឯកឧត្តម **ឃិត បុណ្ណា** | រដ្ឋលេខាធិការ | សមាជិក |
| ៨. ឯកឧត្តម **ឈួន ទិន** | រដ្ឋលេខាធិការ | សមាជិក |
| ៩. ឯកឧត្តម **លុច្ស រចនា** | រដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យ | សមាជិក |
| ១០. ឯកឧត្តម **ង៉ាស៊ីម សុរិយា** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១១. ឯកឧត្តម **នូ វឌ្ឍនៈ** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១២. ឯកឧត្តម **គីម សាន់** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១៣. ឯកឧត្តម **នឹម សុធា** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១៤. ឯកឧត្តម **សុន សុខគេច** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១៥. ឯកឧត្តម **ម៉ី ម៉ារ៉ាឌី** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១៦. ឯកឧត្តម **កែន រដ្ឋា** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ១៧. ឯកឧត្តម **សឿន ប៊ុនលី** | អគ្គនាយកផែនការ និងគោលនយោបាយ | សមាជិក |
| ១៨. ឯកឧត្តម **ហេង រត្នពិសិដ្ឋ** | អគ្គនាយកសាធារណការ | សមាជិក |
| ១៩. ឯកឧត្តម **ហ៊ាង ខុន្ធា** | អគ្គនាយកបច្ចេកទេស | សមាជិក |
| ២០. ឯកឧត្តម **ឈួន វ៉ាន់** | អគ្គនាយកដឹកជញ្ជូនផ្លូវគោក | សមាជិក |
| ២១. ឯកឧត្តម **ឈៀង ពេជ្រ** | អគ្គនាយកភស្តុភារកម្ម | សមាជិក។ |

**ប្រការ២.-**

គណៈកម្មការចំពោះកិច្ចនេះ មានភារកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម៖

- រៀបចំធ្វើវិសោធនកម្មច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងសិក្សាបច្ចេកទេសឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីកំណត់ប្រភេទយានយន្ត និងប្រភេទផ្លូវសម្រាប់ការដំឡើងទម្ងន់កម្រិតកំណត់ពី ៤០តោន ទៅ ៤៥តោន
- សិក្សា និងរៀបចំយន្តការឱ្យបានច្បាស់លាស់ក្នុងការផ្តល់ការលើកទឹកចិត្តដល់មន្ត្រីពាក់ព័ន្ធទាំងអស់នឹងការងារត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- សិក្សា និងលើកផែនការដាក់ការបន្ថែមទីតាំងស្ថានីយត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ សម្រាប់រយៈពេលខ្លី មធ្យម និងវែង
- សិក្សា និងលើកផែនការធ្វើទំនើបកម្មស្ថានីយត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ តាមប្រព័ន្ធបច្ចេកវិទ្យាទំនើប
- សិក្សា និងរៀបចំទីតាំងសម្រាប់រក្សាទុករថយន្តល្មើសនឹងការដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- សិក្សា និងរៀបចំនីតិវិធីស្តង់ដារប្រតិបត្តិនៃការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- បំពេញភារកិច្ចផ្សេងទៀតពាក់ព័ន្ធនឹងការដោះស្រាយបញ្ហាប្រឈមលើការងារត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់។

**ប្រការ៣.-**

គណៈកម្មការចំពោះកិច្ចនេះ មានលេខាធិការដ្ឋានមួយជាសេនាធិការ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ម៉ី ម៉ារ៉ាឌី** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២. លោក **ពៅ ឡាធី** | អគ្គនាយករងផែនការ និងគោលនយោបាយ | អនុប្រធាន |
| ៣. លោក **ណៃ ចំណាច់** | អគ្គនាយករងសាធារណការ | សមាជិក |
| ៤. លោក **កុយ រតនៈបណ្ឌិត** | អគ្គនាយករងបច្ចេកទេស | សមាជិក |
| ៥. លោកស្រី **ម៉ែន ច័ន្ទសុកុល** | ប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក | សមាជិកា |
| ៦. លោក **សំ មុំណែល** | ប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |
| ៧. លោក **ឃុន សីហា** | ប្រធាននាយកដ្ឋានរដ្ឋបាល និងទំនាក់ទំនងសាធារណៈ | សមាជិក |
| ៨. លោក **ពន្លក ផល្លា** | នាយករងខុទ្ទកាល័យ | សមាជិក |
| ៩. លោក **មាស ម៉ូនីភារណាគី** | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ | សមាជិក |
| ១០. លោក **តាំង ពៅ** | អនុប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក | សមាជិក |
| ១១. លោក **អ៊ុយ សម្បត្តិ** | ប្រធានការិ. នៃនាយកដ្ឋានផែនការ | សមាជិក |
| ១២. លោកស្រី **ខុឡឺ សុនីកា** | អនុប្រធានការិ. នៃនាយកដ្ឋានហិរញ្ញវត្ថុ | សមាជិកា |
| ១៣. លោក **ឧច់ សុតី** | អនុប្រធានការិ. នៃនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក និងសំណង់កំពង់ផែ | សមាជិក |
| ១៤. លោក **សេង សុវណ្ណារុណ** | អនុប្រធានការិ. នៃនាយកដ្ឋានពិនិត្យតាមដាន និងវាយតម្លៃ | សមាជិក |
| ១៥. លោក **ជឹម មករា** | មន្ត្រីនៃនាយកដ្ឋានគ្រឿងចក្រ និងស្ថាបនាផ្លូវ | សមាជិក។ |

**ប្រការ៤.-**

លេខាធិការដ្ឋាននៃគណៈកម្មការចំពោះកិច្ចនេះ មានភារកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម៖

- ធ្វើជាសេនាធិការជូនគណៈកម្មការចំពោះកិច្ច
- សម្របសម្រួល និងអនុវត្តការងារប្រចាំថ្ងៃ តាមការណែនាំរបស់គណៈកម្មការចំពោះកិច្ច
- ពិនិត្យលិខិតស្នាម និងឯកសារផ្សេងៗ ដើម្បីដាក់ជូនគណៈកម្មការចំពោះកិច្ច
- រៀបចំ និងបូកសរុបរបាយការណ៍វឌ្ឍនភាពការងារ និងធ្វើកំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈកម្មការចំពោះកិច្ច
- បំពេញភារកិច្ចផ្សេងៗទៀតតាមការណែនាំរបស់ប្រធានគណៈកម្មការចំពោះកិច្ច។

**ប្រការ៥.-**

អនុប្រធាន សមាជិកនៃគណៈកម្មការចំពោះកិច្ចនេះ ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានគណៈកម្មការចំពោះកិច្ចអវត្តមាន អនុប្រធានអាចកោះអញ្ជើញ និងដឹកនាំកិច្ចប្រជុំជំនួសតាមការប្រគល់សិទ្ធិរបស់ប្រធាន។

គណៈកម្មការចំពោះកិច្ចនេះ មានសិទ្ធិអញ្ជើញភាគីពាក់ព័ន្ធ ឬដៃគូអភិវឌ្ឍន៍ ចូលរួមកិច្ចប្រជុំតាមការចាំបាច់។

**ប្រការ៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧.-**

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថានតេជោសែនសាធារណការ និងដឹកជញ្ជូន ប្រធាននាយកដ្ឋាន ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត និងប្រធានអង្គភាពក្រោមឱវាទក្រសួង ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ និងប្រការ៣ ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារនៃសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ប៉េង ពោធិ៍នា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- លោកជំទាវរដ្ឋលេខាធិការប្រចាំការ
- ខុទ្ទកាល័យរដ្ឋមន្ត្រី
- ដូចប្រការ៧
- ឯកសារ-កាលប្បវត្តិ